# ផលិតកម្មដំណាំត្របែកសំរាប់កសិករ




រៀបចំដោយមានការចូលរួមពីអង្គការ សន្តិសេនា សមាគមមនុស្សចាស់

ពោធិធំ អង្គការចិត្តធម៌ និង អង្គការ ស៊ី អារ អែស កម្មវិធីកសិកម្ម

ដកស្រង់ពីឯកសារឈើហូបផ្លែរបស់អង្គការ ម៉ាឌិក ស៊ីដសេ និង សាលាជាតិកសិកម្មព្រែកលៀប

# មាតិការ

ទំព័រ

១- សេចក្តីផ្តើម.........................................................................០១

២-ការជ្រើសរើសពូជ....................................................................០២

៣- ការបណ្តុះកូន .........................................................................០២

ក. ជ្រើសរើសទីតាំងថ្នាល............................................................០២

ខ. ការរៀបចំថ្នាល.........................................................................០២

គ. ការបណ្តុះកូនត្របែក.................................................................០៣

ឃ. ការផ្សាំក្នុងថង់........................................................................០៤

៤- ការដាំដុះ................................................................................០៥

ក. ការជ្រើសរើសទីកន្លែងដាំដុះ.....................................................០៥

ខ. របៀបជីករណ្តៅ.......................................................................០៥

គ. ការដាក់ជីក្នុងរណ្តៅ..................................................................០៦

ឃ. ការដាំកូនត្របែក.....................................................................០៧

៥- ការថែទាំ................................................................................០៧

ក. ការដាក់ជីបំប៉ន.......................................................................០៧

ខ. ការស្រោចទឹក..........................................................................០៨

គ. ការតាក់តែងមែក......................................................................០៨

ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ..........................................១០

៦- ការប្រមូលផល.........................................................................១០

៧- ការបន្តពូជ...............................................................................១០

ក. ការបន្តពូជដោយគ្រាប់................................................................១០

ខ. ការបន្តដោយសាកមែក...............................................................១០

## ១-សេចក្តីផ្តើម

ត្របែកគឺជារុក្ខជាតិមួយដែលកសិករភាគច្រើននិយមដាំ ព្រោះអាចដុះលូតលាស់បានលើដីស្ទើរតែគ្រប់ប្រភេទ។ វាមានប្រយោជន៏ច្រើនយ៉ាងដូចជា ហូបផ្លែស្រស់ជាបង្អែមជ្រក់ ដើមធ្វើជាសំភារៈសង្ហារឹមផ្សេងៗ ជារបាំងខ្យល់ ជាម្លប់ និង ស្លឹកជាជី ។

## ២-ការជ្រើសរើសពូជ

ពូជត្របែកដែលអាចយកមកដាំបាននោះគឺ ពូជឆាប់ផ្លែ ធនជំងឺ ផ្លែធំ សាច់ក្រាស់ រស់ជាតិឆ្ងាញ់ មានប្រភពច្បាស់លាស់ និង តម្រូវការសំរាប់ទីផ្សារខ្ពស់ ។



## ៣-ការបណ្ដុះកូន

### ក. ជ្រើសរើសទីតាំងថ្នាល:

ទីតាំង និង ការរៀបចំថ្នាលជាកត្តាមួយដ៏សំខាន់សំរាប់ធ្វើអោយការដុះពន្លកនៃកូនដំណាំបានគង់វង់ក្នុងបរិមាណខ្ពស់ និង សុខភាពល្អនោះដូចជាៈ- ក្បែរប្រភពទឹកដីទួលមិនលិចទឹក មានពន្លឺគ្រប់គ្រាន់ និង ជាទីកន្លែងដែលមានសុវត្ថិភាព ។

### ខ. ការរៀបចំថ្នាល:

ត្រូវលើកដីថ្នាលអោយបានកំពស់ពីរតឹក ទទឹងមួយម៉ែត្រ និង បណ្ដោយអាស្រ័យទៅតាមប្រវែងជាក់ស្ដែងដែលចង់បាន កាប់ដីអោយម៉ត់ ហាលរយៈពេលពីពីរ ទៅ បីសប្ដាហ៍ ដើម្បីសំលាប់បាក់តេរី ឬ សត្វល្អិតចង្រៃផ្សេងៗ និង ជ្រោយដីរួចជ្រើសយកស្មៅចេញ ។



គ.ការបណ្ដុះកូនត្របែក:

ត្រូវលាងគ្រាប់ត្របែកនិងទឹកអោយបានស្អាតរួចហាល និង កំដៅថ្ងៃ ពីពីរ ទៅ បីថ្ងៃ ពង្រាយគ្រាប់លើរងដែលបានរៀបចំជាស្រេចចំងាយប្រហែលកន្លះតឹក ពីគ្រាប់មួយ ទៅគ្រាប់មួយ លុបដីម៉ត់ពីលើគ្រាប់អោយបានជិតល្អ គ្របកំណាត់ចំបើងចិញ្ច្រាំខ្លី១ ស្រោចទឹកអោយសើមជាប្រចាំ។



## ឃ. <u>ការផ្សាំកូន :</u>

កូនត្របែកត្រូវយកទៅផ្សាំក្នុងថង់បានលុះត្រាណាថង់ត្រូវច្រកដោយដីកំប៉ុស្ដិ៍មួយភាគ អង្កាមមួយភាគ និង ដីខ្សាច់មួយភាគជាស្រេច ហើយស្រោចទឹកភ្លាមដើម្បីអោយឬស ចាប់ជាប់ ជាមួយយដីថ្មីក្នុងថង់។

